01109411

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

ឯកសារលេខ៖ ២

*ភាគនាមប្រជារាស្ត្រខ្មែរ និងភាគនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងលេខ៖ ១៧-០២-២០១៥-អវតក/អបជ

**ចំពោះមុខ៖**
ចៅក្រម ប្រាក់ គីមសាន ប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន៉ី ថុល
ចៅក្រម Steven J. BWANA
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ៖** ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 22 / 06 / 2015
ម៉ោង (Time/Heure): 14:12
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

## សម្ងាត់ (សំណៅកោសលុប)

## សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងសេចក្តីសម្រេចរបស់ អង្គភាពគាំពារការការពារក្តី ឆ្លើយតបទៅនឹងសំណើសុំចុះឈ្មោះក្នុងបញ្ជីមេធាវីបរទេស

---

**ម្ចាស់បណ្តឹងឧទ្ធរណ៍៖**
[redacted]

**ប្រធានអង្គភាពគាំពារការការពារក្តី៖**
[redacted]

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C. * C.E.T.C.

01109412

សំណុំរឿង ១៧-០២-២០១៥-អវតក/អបជ

ឯកសារលេខ៖ ២

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានទទួលបណ្តឹងឧទ្ធរណ៍នៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៥ ដាក់ដោយ [redacted] ("ម្ចាស់បណ្តឹងឧទ្ធរណ៍") ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គភាពគាំពារការការពារក្តី បដិសេធសំណើសុំចុះឈ្មោះក្នុងបញ្ជីមេធាវីបរទេស ("បណ្តឹងឧទ្ធរណ៍")[1]។

## I. រំឭកនីតិវិធី

១. នៅថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៥ ម្ចាស់បណ្តឹងឧទ្ធរណ៍ បានដាក់សំណើ សុំចុះឈ្មោះនៅក្នុងបញ្ជីមេធាវីបរទេសដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងការធ្វើជាតំណាងឱ្យជនសង្ស័យ ជនត្រូវចោទ ឬក៏ជនជាប់ចោទក្រីក្រ នៅចំពោះមុខ អ.វ.ត.ក ដែលមានអង្គភាពគាំពារការការពារក្តីជាអ្នករក្សាទុកនូវបញ្ជីនេះ ("បញ្ជីមេធាវី" និងសំណើសុំចុះឈ្មោះរបស់លោក SORAB )[2]។

២. នៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៥ សំណើម្ចាស់បណ្តឹងឧទ្ធរណ៍ ត្រូវបានអង្គភាពគាំពារការការពារក្តីបដិសេធចោល ក្រោមហេតុផលថា លោកមិនមានបទពិសោធន៍វិជ្ជាជីវៈគ្រប់គ្រាន់ ដូចមានតម្រូវក្នុងប្រការ ២.២ នៃបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការការពារក្តី ("សេចក្តីសម្រេចរបស់អង្គភាពគាំពារការការពារក្តី")។ សេចក្តីសម្រេចនេះបញ្ជាក់យ៉ាងច្បាស់ថា ម្ចាស់បណ្តឹងឧទ្ធរណ៍ មិនបានបំពេញនូវលក្ខខណ្ឌដែលតម្រូវឱ្យមានបទពិសោធន៍រយៈពេល១០ឆ្នាំយ៉ាងតិច ក្នុងការអនុវត្តអាជីពជាមេធាវី ចៅក្រម ឬព្រះរាជអាជ្ញា ឬក៏ស្ថិតក្នុងសមត្ថភាពស្រដៀងគ្នាដទៃទៀត[3]។

៣. នៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៥ ម្ចាស់បណ្តឹងឧទ្ធរណ៍ បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេច

---

[1] បណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធសំណើសុំចុះឈ្មោះនៅក្នុងប[illegible]ទេស របស់អង្គភាពគាំពារការការពារក្តី ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ ១ ។

[2] ពាក្យសុំចុះឈ្មោះ-សហមេធាវីបរទេស ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ ១.១.៥ ។

[3] លិខិតរបស់ប្រធានអង្គភាពគាំពារការការពារក្តី ជូន [redacted] មានចំណងជើងថា "សេចក្តីសម្រេចលើសំណើ[illegible] សុំចុះឈ្មោះក្នុងបញ្ជីមេធាវីបរទេស របស់អង្គភាពគាំពារការការពារក្តី" ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ ១.១.៤ កថាខណ្ឌ ៥។

របស់អង្គភាពគាំពារការការពារក្តី ដែលបានបដិសេធចោលសំណើសុំរបស់គាត់ ហើយគាត់ក៏បានស្នើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពលើសេចក្តីសម្រេចនេះ និងស្នើសុំបញ្ចូលឈ្មោះរបស់ខ្លួនទៅក្នុងបញ្ជីមេធាវី។ ម្ចាស់បណ្តឹងឧទ្ធរណ៍ លើកឡើងថា បណ្តឹងឧទ្ធរណ៍របស់គាត់អាចទទួលយកបានដោយអនុលោមតាមវិធាន ១១ (៥) នៃវិធានផ្ទៃក្នុង[4]។ ដោយផ្អែកលើអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍ គាត់បានអះអាងថា អង្គភាពគាំពារការការពារក្តីបានអនុវត្តលក្ខណៈវិនិច្ឆ័យមិនត្រឹមត្រូវក្នុងការវាយតម្លៃពីរយៈពេលនៃបទពិសោធន៍ការងាររបស់គាត់[5] ហើយម្យ៉ាងវិញទៀត អង្គភាពគាំពារការការពារក្តីមិនបានវាយតម្លៃឱ្យបានត្រឹមត្រូវពីប្រភេទនៃបទពិសោធន៍ការងាររបស់គាត់នោះទេ[6]។ លើសពីនេះទៅទៀត លោកបានស្តីបន្ទោសលើសេចក្តីសម្រេចរបស់អង្គភាពគាំពារការការពារក្តីថា បានធ្វើការពិចារណាតែលើបទពិសោធន៍ការងាររបស់គាត់ ក្រោយពីទទួលបានបរិញ្ញាប័ត្រផ្នែកច្បាប់តែប៉ុណ្ណោះ[7]។

៤. នៅថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៥ ដោយមានការស្នើសុំពីអង្គបុរេជំនុំជម្រះ អង្គភាពគាំពារការការពារក្តីបានផ្តល់ឯកសារឆ្លងឆ្លើយគ្នាមួយច្បាប់រវាងអង្គភាពគាំពារការការពារក្តីជាមួយនឹងម្ចាស់បណ្តឹងឧទ្ធរណ៍ ពាក់ព័ន្ធនឹងសំណើរបស់អង្គភាពសុំឱ្យមានការបញ្ជាក់លើមុខងារមួយចំនួនដែលលោកធ្លាប់បានបំពេញកាលពីពេលមុន[8]។

## II. ភាពទទួលយកបាននៃបណ្តឹងឧទ្ធរណ៍របស់[redacted]

៥. យោងតាមវិធាន ១១ (៥) នៃវិធានផ្ទៃក្នុង "មេធាវី ឬ ជំនួយការរបស់ខ្លួន ដែលពាក្យសុំចុះឈ្មោះ

---

[4] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣-៤។

[5] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១០-១១។

[6] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១២-១៩។

[7] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២០។

[8] អ៊ីមែលរបស់ប្រធានអង្គភាពគាំពារការការពារក្តី ផ្ញើជូនក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៥ ដោយមានភ្ជាប់ជាមួយនូវអ៊ីមែលផ្ញើជូន[redacted] កាលពីថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៥ មានចំណងជើងថា "សំណើសុំការបំភ្លឺ" និងចម្លើយរបស់[redacted] នៅថ្ងៃតែមួយ។
*សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់*[redacted] *ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គភាពគាំពារការការពារក្តី ឆ្លើយតបទៅនឹងសំណើសុំចុះឈ្មោះក្នុងបញ្ជីមេធាវីបរទេស*

របស់ពួកគេ សម្រាប់ការពារជនក្រីក្រ ដូចមានចែងនៅក្នុងអនុវិធាន ២ ចំណុច (ឃ) និង (ឈ) ខាងលើ ត្រូវបានបដិសេធ [...] អាចប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលសេចក្តីជូនដំណឹងពីសេចក្តីសម្រេចរបស់ប្រធានអង្គភាពគាំពារការការពារក្តី" ។

៦. ដូច្នេះ ដូចដែលត្រូវបានបញ្ជាក់ពីខាងដើម ម្ចាស់បណ្តឹងឧទ្ធរណ៍ បានដាក់សំណើសុំចុះឈ្មោះនៅថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៥។ សំណើនេះត្រូវបានអង្គភាពគាំពារការការពារក្តីបដិសេធចោល តាមរយៈអ៊ីមែលឆ្លងឆ្លើយរបស់ប្រធានអង្គភាពគាំពារការការពារក្តី ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៥។

៧. ម្ចាស់បណ្តឹងឧទ្ធរណ៍ បានដាក់សារណាប្តឹងឧទ្ធរណ៍ និងឧបសម្ព័ន្ធរបស់សារណានេះ នៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៥។ ដូច្នេះ បណ្តឹងឧទ្ធរណ៍របស់លោក SORAB អាចទទួលយកបាន។

## III. ការពិនិត្យលើអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍

### ក. លក្ខណៈវិនិច្ឆ័យក្នុងការពិនិត្យលើបណ្តឹងឧទ្ធរណ៍

៨. ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយអនុលោមតាមវិធាន ១១ (៥) នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះត្រូវពិនិត្យមើលថាតើ ប្រធានអង្គភាពគាំពារការការពារក្តី៖

ក) បានអនុវត្តតាមលក្ខខណ្ឌតម្រូវគតិយុត្តពាក់ព័ន្ធ។

ខ) បានអង្កេតវិធានមូលដ្ឋាននៃយុត្តិធម៌តាមច្បាប់ធម្មជាតិ ឬអនុវត្តតាមភាពត្រឹមត្រូវផ្នែកនីតិវិធី។

គ) បានពិចារណាលើសម្ភារៈមិនពាក់ព័ន្ធ ឬខកខានមិនបានពិចារណាលើសម្ភារៈពាក់ព័ន្ធ ឬ

ឃ) បានធ្វើសេចក្តីសន្និដ្ឋានដែលបុគ្គលមានហេតុផល មិនអាចធ្វើសេចក្តីសន្និដ្ឋានបែបនេះ

ដោយផ្អែកតាមសម្ភារៈដែលមាននៅចំពោះមុខគាត់[9]។

## ខ. លក្ខណៈវិនិច្ឆ័យពាក់ព័ន្ធនឹងបទពិសោធន៍តម្រូវ ដើម្បីអាចចុះឈ្មោះបាននៅក្នុងបញ្ជីមេធាវី

៩. ម្ចាស់បណ្តឹងឧទ្ធរណ៍ យល់ឃើញថា អង្គភាពគាំពារការការពារក្តីពុំបានអនុវត្តលក្ខណៈវិនិច្ឆ័យដែលពាក់ព័ន្ធនោះទេ។ បើតាមម្ចាស់បណ្តឹងឧទ្ធរណ៍ អង្គភាពគាំពារការការពារក្តីមានការភាន់ច្រឡំ ដោយបានអនុវត្តប្រការ ២.២ នៃបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការការពារក្តី ព្រោះថា បញ្ញត្តិនេះផ្ទុយគ្នាទៅនឹងវិធាន ១១ (៤) (គ) (៣) នៃវិធានផ្ទៃក្នុង និងបានចែងពីលក្ខណៈវិនិច្ឆ័យមួយចំនួនដែលរឹតត្បិតជាទីបំផុត[10]។ ក៏ប៉ុន្តែ ម្ចាស់បណ្តឹងឧទ្ធរណ៍ បានលើកឡើងថា វិធានផ្ទៃក្នុងពិតជាមានអានុភាពលើបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការការពារក្តី។ ហេតុដូច្នេះ ម្ចាស់បណ្តឹងឧទ្ធរណ៍ បានអះអាងថា នៅពេលធ្វើការពិនិត្យលើបទពិសោធន៍ការងាររបស់គាត់ វាពិតជាមិនតម្រូវឱ្យពិនិត្យមើលថាតើការងារដែលគាត់បានបំពេញពីមុនមក គឺជាការងារតែមួយដូចគ្នាទៅនឹងការងាររបស់ព្រះរាជអាជ្ញា ចៅក្រម ឬមេធាវី នោះទេ។ លោកយល់ឃើញថា ការមានបទពិសោធន៍ពាក់ព័ន្ធទៅនឹងនីតិវិធីព្រហ្មទណ្ឌ ជាការគ្រប់គ្រាន់ណាស់ទៅហើយ[11]។ អ្វីដែលគួរឱ្យកត់សម្គាល់នោះគឺថា នៅក្នុងការសរសេរសារណារបស់ខ្លួន ម្ចាស់បណ្តឹងឧទ្ធរណ៍ ហាក់ដូចជាបានយោងតែទៅលើវិធានផ្ទៃក្នុងជាភាសាអង់គ្លេសតែមួយប៉ុណ្ណោះ។

១០. អង្គបុរេជំនុំជម្រះសូមធ្វើការកត់សម្គាល់ភ្លាមៗថា វិធានផ្ទៃក្នុងពុំបានចែងអំពីលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសយកមេធាវីបរទេសឱ្យតំណាងជនសង្ស័យ ជនត្រូវចោទ និងជនជាប់ចោទក្រីក្រនៅចំពោះមុខ អ.វ.ត.ក នោះទេ ដោយបទបញ្ជាផ្ទៃក្នុងបានផ្តល់អំណាចនេះទៅឱ្យអង្គភាពគាំពារការការពារក្តី ក្នុងការកំណត់អំពីលក្ខណៈវិនិច្ឆ័យទាំងអស់នេះ ក្នុងក្របខណ្ឌមួយដែលកំណត់ដោយ

---

[9] សំណុំរឿង ១០-០៧-២០១៣-អវតក-អបជ សាលដីកាលើ "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធពាក្យសុំរបស់ [redacted] សុំឱ្យបញ្ចូលឈ្មោះនៅក្នុងបញ្ជីឈ្មោះសហមេធាវី" ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ ៨ កថាខណ្ឌ [illegible]។

[10] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១០។

[11] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១១។

វិធាន ១១ (៤) នៃវិធានផ្ទៃក្នុង។ ត្រង់ចំណុចនេះ វិធាន ១១ (២) នៃវិធានផ្ទៃក្នុង ចែងថា៖ "អង្គភាពនេះ [អង្គភាពគាំពារការការពារក្ដី] ត្រូវបំពេញមុខងាររបស់ខ្លួនដូចជា៖ ក-អនុម័តបទបញ្ជារដ្ឋបាលស្របទៅនឹងវិធាន ៤ នៃវិធានផ្ទៃក្នុងនេះ ក្រោយពេលពិគ្រោះយោបល់រវាងប្រធានអង្គភាពនេះ ជាមួយនឹងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា រួមមាន៖ ១) លក្ខណៈវិនិច្ឆ័យ និងនីតិវិធីក្នុងការចុះឈ្មោះមេធាវី និងបុគ្គលិកដទៃទៀតទៅក្នុងបញ្ជី ដូចមានក្នុងចំណុច (ឃ) និង (ឈ) ខាងក្រោមដោយស្របទៅនឹងអនុវិធាន ៤"។ លើសពីនេះទៀត វិធាន ១១ ៤) ចែងថា៖ "លក្ខណៈវិនិច្ឆ័យក្នុងការចុះឈ្មោះមេធាវីក្នុងបញ្ជីនៅក្នុងអង្គភាពគាំពារការការពារក្ដី ដើម្បីការពារជនត្រឹក្រនៅចំពោះមុខអ.វ.ត.ក ដូចមានចែងក្នុងអនុវិធាន ២ (ឃ) ខាងលើ ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម [...]"។ ដូច្នេះ វាច្បាស់ណាស់ថា អង្គភាពគាំពារការការពារក្ដីមិនត្រឹមតែជាអ្នកមាននីតិសម្បទាក្នុងការធ្វើកិច្ចការនេះនោះទេ តែវាក៏ជាកាតព្វកិច្ចរបស់អង្គភាពមួយនេះដែរ ដែលត្រូវអនុម័តនូវបទបញ្ជារដ្ឋបាល ដោយត្រូវចែងអំពីលក្ខណៈវិនិច្ឆ័យក្នុងការជាប់ឈ្មោះក្នុងបញ្ជីមេធាវី។ បញ្ហាចោទនៅពេលនេះគឺថា តើអង្គភាពគាំពារការការពារក្ដីបានធ្វើកិច្ចការហួសពីក្របខណ្ឌដែលវិធាន ១១ (៤) (គ) (៣) នៃវិធានផ្ទៃក្នុង បានកំណត់ដែរឬទេ។

១១. ពាក់ព័ន្ធនឹងចំណុចនេះ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា បទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការការពារក្ដីក្នុងសំណៅជាភាសាបារាំង អង់គ្លេស និងខ្មែរ ពិតជាមានខ្លឹមសារស៊ីសង្វាក់គ្នាដោយបានយកទាំងស្រុងនូវលក្ខណៈវិនិច្ឆ័យដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង ក្នុងសំណៅជាភាសាបារាំង ដោយតម្រូវឱ្យបេក្ខជនធ្វើការបញ្ជាក់ថាខ្លួន "មានបទពិសោធន៍ការងារជាមេធាវី ចៅក្រម ឬ ព្រះរាជអាជ្ញា ឬ ក្នុងសមត្ថភាពស្រដៀងគ្នាដទៃទៀតយ៉ាងតិច១០(ដប់)ឆ្នាំ" (យើងជាអ្នកគូសបន្ទាត់ពីក្រោម)។ លក្ខណៈវិនិច្ឆ័យនេះមានចែងក្នុងប្រការ ២.២ នៃបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការការពារក្ដី ជាភាសាអង់គ្លេស៖ "In order to be included in the UNAKRT list as foreign co-lawyer, the candidate must fulfil each of the followings requirements: (iii) to have at least ten years working experience in criminal proceedings, as a lawyer, judge or prosecutor or in some other similar capacity"។ មាត្រានេះជាភាសាខ្មែរ ក៏បានបញ្ជាក់ផងដែរពីលក្ខខណ្ឌតម្រូវសម្រាប់ការងារប្រហាក់ប្រហែលនេះដែរ។

១២. "៣-ត្រូវមានបទពិសោធន៍ការងារជាមេធាវី ចៅក្រម ឬ ព្រះរាជអាជ្ញា ឬ ក្នុងសមត្ថភាពស្រដៀងគ្នាដទៃទៀតយ៉ាងតិច១០(ដប់)ឆ្នាំ ក្នុងរឿងក្តីព្រហ្មទណ្ឌ"។

១៣. ផ្ទុយមកវិញ វិធាន ១១ (៤) (គ) (៣) នៃវិធានផ្ទៃក្នុង ជាភាសាអង់គ្លេស និងខ្មែរ ពិតជាមិនមានភាពស៊ីសង្វាក់គ្នាជាមួយនឹងភាសាបារាំង។ ឧទាហរណ៍ ភាសាអង់គ្លេសបានសរសេរថា បេក្ខជនត្រូវ "មានបទពិសោធន៍ការងារដប់ឆ្នាំក្នុងផ្នែកនីតិវិធីព្រហ្មទណ្ឌជាមេធាវី ចៅក្រម ឬព្រះរាជអាជ្ញា ឬក៏សមត្ថភាពផ្សេងទៀត"។ ភាសាខ្មែរ ក៏បានសរសេរពាក្យស្រដៀងគ្នាដែរថា "៣-មានបទពិសោធន៍ការងារជាមេធាវី ចៅក្រម ឬ ព្រះរាជអាជ្ញា ឬក្នុងមុខងារផ្សេងទៀតយ៉ាងតិច១០(ដប់)ឆ្នាំ ក្នុងរឿងក្តីព្រហ្មទណ្ឌ"។

១៤. អង្គបុរេជំនុំជម្រះយល់ឃើញថា វិធាន ១១ (៤) (គ) (៣) នៃវិធានផ្ទៃក្នុង ជាភាសាអង់គ្លេស និងខ្មែរ ពិតជាមានភាពមិនច្បាស់លាស់ ហើយបើតាមខ្លឹមសារនៃវិធាននេះ គឺរាល់បេក្ខជនណាដែលមានបទពិសោធន៍ការងារដប់ឆ្នាំក្នុងរឿងក្តីព្រហ្មទណ្ឌ ទោះបីជាក្នុងសមត្ថភាពវិជ្ជាជីវៈបែបណាក៏ដោយ តែក្នុងលក្ខខណ្ឌដែលបទពិសោធន៍ទាំងនោះត្រូវតែពាក់ព័ន្ធនឹងផ្នែកនីតិវិធីព្រហ្មទណ្ឌ ពិតជាអាចសុំចុះឈ្មោះក្នុងបញ្ជីមេធាវីបរទេសបាន។ ដូច្នេះ អ្នកមានអាជីពជាអ្នកស៊ើបអង្កេតផ្នែកព្រហ្មទណ្ឌម្នាក់ ដែលមានបទពិសោធន៍ការងារដប់ឆ្នាំ ដែលក្នុងនោះ បទពិសោធន៍ទាំងស្រុងទទួលបានមកពីការងារក្រៅក្របខណ្ឌនៃការិយាល័យមេធាវី ឬក៏ពីតុលាការ ពិតជាអាចសុំបំពេញមុខងារជាមេធាវីបាន។ ប៉ុន្តែ នៅក្នុងវិធានផ្ទៃក្នុងជាភាសាបារាំង វិធាន ១១ (៤) (គ) (៣) ដដែលនេះ បានចែងយ៉ាងច្បាស់ ដោយបានតម្រូវឱ្យបេក្ខជន ១) មានបទពិសោធន៍ការងារដប់ឆ្នាំ ២) ក្នុងផ្នែកនីតិវិធីព្រហ្មទណ្ឌ និង ៣) ជាមេធាវី ចៅក្រម ឬព្រះរាជអាជ្ញា ឬក៏សមត្ថភាពប្រហាក់ប្រហែលផ្សេងទៀត។

១៥. អង្គបុរេជំនុំជម្រះយល់ឃើញថា តាមរយៈការអនុម័តបទបញ្ជារដ្ឋបាលរបស់ខ្លួន អង្គភាពគាំពារការការពារក្តីពិតជាមាននីតិសម្បទាក្នុងការធ្វើការបកស្រាយបំភ្លឺអំពីប្រភេទនៃបទពិសោធន៍ការងារតម្រូវសម្រាប់ទទួលបានការចុះឈ្មោះនៅក្នុងបញ្ជីមេធាវី ដែលបទពិសោធន៍ទាំងនោះត្រូវបាន



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C C.E.T.C

រៀបរាប់ជាពាក្យពេចន៍មិនច្បាស់លាស់នៅក្នុងបទបញ្ជាររដ្ឋបាលជាភាសាអង់គ្លេស និងខ្មែរ ដើម្បីផ្តល់ក្របខណ្ឌមួយច្បាស់លាស់ដល់សេចក្តីសម្រេចរបស់ខ្លួន និងចៀសវាងធ្លាក់ទៅក្នុងការអនុវត្តតាមទំនើងចិត្ត។ ការកំណត់ពីលក្ខណៈវិនិច្ឆ័យលើបទពិសោធន៍ការងារ ដែលដកចេញយ៉ាងច្បាស់ចេញពីលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងវិធានផ្ទៃក្នុងជាភាសាបារាំង បង្ហាញឱ្យឃើញថាអង្គភាពគាំពារការការពារក្តីបានអនុម័តបទបញ្ជាមួយ ទាញចេញពី "គោលការណ៍" និងខ្លឹមសារនៃវិធាន ១១ (៤) នៃវិធានផ្ទៃក្នុង។ គេអាចនិយាយបែបម្យ៉ាងទៀតថា ខ្លឹមសាររួមដែលមានចែងក្នុងវិធានផ្ទៃក្នុងជាភាសាបារាំង និងក្នុងបទបញ្ជាររដ្ឋបាលរបស់អង្គភាពគាំពារការការពារក្តី ទាំងបីភាសា គឺជាបណ្តុំនៃអត្ថបទគតិយុត្តដែលមានភាពស៊ីសង្វាក់គ្នា និងមានភាពច្បាស់លាស់គ្រប់គ្រាន់។ ដូច្នេះវាមិនត្រូវកែប្រែដោយមិនត្រឹមត្រូវនូវលក្ខណៈវិនិច្ឆ័យនៃការចុះឈ្មោះ ដូចដែលមានចែងក្នុងវិធាន ១១ (៤) (គ) (៣) នៃវិធានផ្ទៃក្នុង នោះទេ ព្រោះថា ប្រកា ២.២ នៃបទបញ្ជាររដ្ឋបាលរបស់អង្គភាពគាំពារការការពារក្តី គោរពបានយ៉ាងត្រឹមត្រូវនូវបញ្ញត្តិនៃវិធានមួយនេះ។

១៦. លើសពីនេះទៅទៀត សេចក្តីសម្រេចក្នុងការតាក់តែងពាក្យក្នុងបទបញ្ជាររដ្ឋបាល ដូចដែលមានចែងក្នុងវិធានផ្ទៃក្នុងជាភាសាបារាំង គឺពិតជាត្រឹមត្រូវទៅនឹងវិធាននៃការបកស្រាយ ដូចមានកំណត់ក្នុងមាត្រា ២១ (១) នៃវិធានផ្ទៃក្នុង ដែលចែងថា៖ "ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជាររដ្ឋបាល ទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និង ជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង"។ ក៏ប៉ុន្តែ អង្គបុរេជំនុំជម្រះយល់ឃើញថា វាជាការស្របតាមផលប្រយោជន៍របស់ជនសង្ស័យ និងជនត្រូវចោទក្នុងការទទួលបានមេធាវីម្នាក់ ដែលមានបទពិសោធន៍កាន់តែស្រដៀងគ្នាបំផុតតាមដែលអាចធ្វើទៅបាន ទៅនឹងសេវាកម្មដែលខ្លួនត្រៀមបំពេញសម្រាប់កូនក្តីរបស់ខ្លួន។ ដូចដែលអង្គជំនុំជម្រះសាលាដំបូង នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា បានរំឭកថា "បទប្បញ្ញត្តិទាំងនេះ [ពាក់ព័ន្ធនឹងលក្ខខណ្ឌនានាក្នុងការចាត់តាំងឱ្យការពារជនជាប់ចោទក្រីក្រ] មានគោលដៅធ្វើយ៉ាងណាឱ្យក្រុមមេធាវីការពារក្តីដែលទទួលបានការចាត់តាំង បង្ហាញភ័ស្តុតាងឱ្យឃើញពីមេធាវីជំនាញ



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ពាក់ព័ន្ធ ដែលទទួលបានក្នុងរយៈពេលជាច្រើនឆ្នាំ និងក្នុងកម្រិតខ្ពស់បំផុត ដើម្បីជាប្រយោជន៍ដល់ការរៀបចំការការពារក្តីប្រកបដោយប្រសិទ្ធភាពសម្រាប់ជនជាប់ចោទ"[12]។

១៧. ម្ចាស់បណ្តឹងឧទ្ធរណ៍ លើកឡើងដោយពុំត្រឹមត្រូវថា អង្គភាពគាំពារការការពារក្តីគួរតែផ្ទៀងផ្ទាត់ថា តើ គាត់បានបំពេញនូវលក្ខណៈវិនិច្ឆ័យដែលតម្រូវឱ្យមានបទពិសោធន៍ការងាររយៈពេលដប់ឆ្នាំ ក្នុងមុខងារណាមួយក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌដែរឬទេ។ ពិតណាស់ថា មុខងារដែលបានលើកឡើងនេះ មិនត្រូវដូចគ្នាទាំងស្រុងទៅនឹងមុខងារជាមេធាវី ចៅក្រម ឬសហព្រះរាជអាជ្ញា នោះទេ ព្រោះថាបើមិនដូច្នោះទេ ការបើកទូលាយចំពោះមុខងារផ្សេងៗទៀតនឹងលែងមានអត្ថន័យតទៅទៀតហើយ។ ប៉ុន្តែ មុខងារទាំងឡាយដែលបេក្ខជនបានលើកឡើង ត្រូវតែមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងមុខងារដែលបំពេញដោយមេធាវី ចៅក្រម ឬ ព្រះរាជអាជ្ញា ដែលស្នើសុំចុះឈ្មោះក្នុងបញ្ជីមេធាវីបរទេស ដែលរក្សាទុកដោយអង្គភាពគាំពារការការពារក្តី។

**គ. ការពិនិត្យលើបទពិសោធន៍ការងាររបស់** ម្ចាស់បណ្តឹងឧទ្ធរណ៍

១៨. ទោះបីជាអង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា អង្គភាពគាំពារការការពារក្តីមិនបានប្រព្រឹត្តកំហុស ក្នុងការកំណត់អំពីលក្ខណៈវិនិច្ឆ័យពាក់ព័ន្ធនឹងបទពិសោធន៍ការងារតម្រូវសម្រាប់ការសុំចុះឈ្មោះនៅក្នុងបញ្ជីមេធាវីក៏ដោយ ក៏អង្គបុរេជំនុំជម្រះនឹងចាប់ផ្តើមពិនិត្យមើលថា តើអង្គភាពមួយនេះបានប្រព្រឹត្តកំហុសក្នុងការអនុវត្តលក្ខណៈវិនិច្ឆ័យនេះ លើបញ្ហាដែលកំពុងចោទឡើងនេះដែរឬទេ។

១៩. អង្គភាពគាំពារការការពារក្តីយល់ឃើញថា ទោះបីជា ម្ចាស់បណ្តឹងឧទ្ធរណ៍ ពិតជាបានបំពេញភារកិច្ចមួយចំនួនដែលអាចរាប់បញ្ចូលក្នុងការគណនាពីរយៈពេលបទពិសោធន៍ការងាររបស់គាត់ក៏ដោយ ក៏បទពិសោធន៍ការងារផ្សេងៗរបស់គាត់ មិនអាចត្រូវបានរាប់បញ្ចូលបានដែរ ដោយហេតុថា កម្រិតនៃការទទួលខុសត្រូវ និងប្រភេទនៃសកម្មភាពដែលបេក្ខជនបានលើកឡើង គឺពិតជាខុស

---

[12] វណ្ណអាជ្ញា តទល់នឹង *Ntakirutimana* សំណុំរឿង ICTR-96-10-T សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី ស្តីពីការតែងតាំងសហមេធាវីសម្រាប់លោក Elizaphan Ntakirutimana អង្គជំនុំជម្រះសាលាដំបូង ១ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០១ កថាខណ្ឌ ១៧។



PRE-TRIAL CHAMBER E.C.C.C. C.E.T.C. CHAMBRE PRELIMINAIRE

គ្នាយ៉ាងខ្លាំងពីលក្ខខណ្ឌតម្រូវដែលមានចែងក្នុងអត្ថបទយោង[13]។

២០. ម្ចាស់បណ្តឹងឧទ្ធរណ៍ បានស្តីបន្ទោសអង្គភាពគាំពារការការពារក្តីថា មិនបានផ្តល់ដល់ខ្លួននូវពិន្ទុបន្ថែមសម្រាប់មុខងាររបស់គាត់ ១) ជាជំនួយការស្រាវជ្រាវសម្រាប់សាស្ត្រាចារ្យ Christine Chinkin និងសាស្ត្រាចារ្យ Gerry Simpson (ការងារពាក់កណ្តាលម៉ោង និងក្នុងពេលដែលគាត់កំពុងសិក្សាផ្នែកច្បាប់ ដែលមួយផ្នែក មុនពេលដែលគាត់បានទទួលបរិញ្ញាប័ត្រផ្នែកច្បាប់) ដែលក្នុងក្របខណ្ឌនៃការងារនេះ គាត់បានចូលរួមក្នុងការរៀបចំមេរៀន និងបានចូលរួមក្នុងកិច្ចអន្តរាគមន៍របស់សាស្ត្រាចារ្យ Chinkin ក្នុងរឿងក្តីមួយនៅចំពោះមុខតុលាការកំពូល និងក្រោយមកទៀត នៅតុលាការកំពូលចក្រភពអង់គ្លេស និងប្រទេសវែល ២) ជាជំនួយការតុលាការ នៅការិយាល័យមេធាវីមួយក្នុងទីក្រុងឡុងដុង ដែលនៅក្នុងមុខងារនេះ គាត់បាននិយាយជាអាទិ៍ថា បានចាត់ចំណាត់ថ្នាក់ និងគ្រប់គ្រងធាតុផ្សំភ័ស្តុតាងរាប់ពាន់ និងធ្វើជាអ្នកបង្ហាញភ័ស្តុតាងក្នុងពេលពិភាក្សាដេញដោល និង ៣) ធ្លាប់ធ្វើជាកម្មសិក្សាការីនៅការិយាល័យរដ្ឋអាជ្ញា នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលក្នុងពេលនោះ គាត់បានធ្វើការស្រាវជ្រាវផ្សេងៗ និងបានពិនិត្យបញ្ហាផ្លូវច្បាប់ថ្មីៗ ដែលបានលើកឡើងចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ។

២១. ទោះបីជាភារកិច្ចទាំងអស់នេះបានអនុញ្ញាតឱ្យម្ចាស់បណ្តឹងឧទ្ធរណ៍ អាចធ្វើឱ្យកាន់តែសុក្រឹតនូវការសិក្សាផ្នែកច្បាប់ព្រហ្មទណ្ឌអន្តរជាតិរបស់គាត់ ហើយអាចឱ្យគាត់ទាញយកប្រយោជន៍ពីការងារទាំងអស់នេះសម្រាប់សកម្មភាពក្រោយៗមកទៀតរបស់គាត់ក៏ដោយ[14] ក៏អង្គបុរេជំនុំជម្រះយល់ឃើញថា ការងារទាំងអស់នេះមានលក្ខណៈខុសគ្នាឆ្ងាយ និងមានកម្រិតទាប បើធៀបទៅនឹងការងារជាមេធាវី ចៅក្រម ឬ ព្រះរាជអាជ្ញា។ ដូចគ្នានេះដែរ លក្ខណៈបែបគរុកោសល្យ ឬបណ្តុះបណ្តាលនៃកម្មសិក្សាមួយ គឺផ្ទុយគ្នាយ៉ាងច្បាស់ទៅនឹងសកម្មភាពជាក់ស្តែង ដែលអ្នកវិជ្ជាជីវៈត្រូវអនុវត្តលើបញ្ហាគតិយុត្ត ឬនីតិវិធីដូចគ្នា។ ដូច្នេះ វាមិនមែនជារឿងដែលគ្មានហេតុផលនោះទេ ចំពោះអង្គភាពគាំពារការការពារក្តី ដែលមិនបានរាប់បញ្ចូលនូវមុខងារទាំងនេះ ដែលម្ចាស់បណ្តឹង

[13] សេចក្តីសម្រេចរបស់អង្គភាពគាំពារការការពារក្តី កថាខណ្ឌ ៧ ៨ និង១០។

[14] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៧។

ខឡូណ៍ ធ្លាប់បានបំពេញពីមុនមក នៅក្នុងពេលធ្វើការគណនាពីរយៈពេលនៃបទពិសោធន៍ការងាររបស់គាត់ ស្របតាមប្រការ ២.២ នៃបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការការពារក្តី។

## ឃ. ចំណុចចាប់ផ្តើមនៃការគណនាបទពិសោធន៍ការងារ

២២. នៅទីបញ្ចប់ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ក្នុងសារណាប្តឹងឧទ្ធរណ៍របស់ខ្លួន ម្ចាស់បណ្តឹងឧទ្ធរណ៍ បានរិះគន់អង្គភាពគាំពារការការពារក្តីថាបានពិចារណាលើបទពិសោធន៍ការងាររបស់គាត់ គិតចាប់តែពីពេលដែលគាត់បានទទួលបរិញ្ញាប័ត្រផ្នែកច្បាប់មកហើយប៉ុណ្ណោះ។ លោក បានលើកឡើងថា អង្គភាពមួយនេះពុំបានបង្ហាញពីភាពត្រឹមត្រូវនៃវិធីសាស្ត្រគណនាបែបនេះនោះទេ ហើយគាត់បានបន្តថា ក្នុងករណីពិសេសរបស់គាត់ បទពិសោធន៍ដែលទទួលបានមុនពេលទទួលបានបរិញ្ញាប័ត្រផ្នែកច្បាប់ គួរតែត្រូវបានចាត់ទុកថាជាបទពិសោធន៍ពាក់ព័ន្ធ។

២៣. បើយោងតាមសេចក្តីសម្រេចដែលរងការប្តឹងឧទ្ធរណ៍ អង្គភាពគាំពារការការពារក្តីបានបង្ហាញថា បានយកពេលដែលបេក្ខជនបានទទួលសញ្ញាប័ត្របរិញ្ញាប័ត្រផ្នែកច្បាប់ ជាចំណុចចាប់ផ្តើមក្នុងការធ្វើការគណនាអំពីរយៈពេលឆ្នាំបទពិសោធន៍ការងាររបស់គាត់[15]។ តែជាក់ស្តែង អង្គភាពគាំពារការការពារក្តីបានធ្វើការពិនិត្យពីភាពពាក់ព័ន្ធនៃបទពិសោធន៍របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ចាប់តាំងពីមុនពេលដែលគាត់ទទួលបានសញ្ញាប័ត្របរិញ្ញាប័ត្រផ្នែកច្បាប់ទៅទៀត ពោលគឺក្នុងពេលដែលគាត់នៅបំពេញការងារជាជំនួយការស្រាវជ្រាវឱ្យសាស្ត្រាចារ្យ Christine Chinkin និងសាស្ត្រាចារ្យ Gerry Simpson ព្រោះថា ការងារស្រាវជ្រាវនេះមានរយៈពេលចាប់ពីខែ មិថុនា ឆ្នាំ ២០០៣ ដល់ខែ មិថុនា ឆ្នាំ ២០០៥ ខណៈដែលលោកបានទទួលសញ្ញាប័ត្របរិញ្ញាប័ត្រផ្នែកច្បាប់ (LL.B.) នៅខែ កក្កដា ឆ្នាំ ២០០៤[16]។

២៤. ក្រោយពីបានអានសេចក្តីសម្រេចរបស់អង្គភាពគាំពារការការពារក្តី អង្គបុរេជំនុំជម្រះយល់ឃើញថា

---

[15] សេចក្តីសម្រេចរបស់អង្គភាពគាំពារការការពារក្តី កថាខណ្ឌ ៦។

[16] សេចក្តីសម្រេចរបស់អង្គភាពគាំពារការការពារក្តី កថាខណ្ឌ ៨ និង ១០។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

អង្គភាពគាំពារការការពារក្តីមិនត្រឹមតែផ្អែកតែទៅលើកាលបរិច្ឆេទនៃការផ្តល់សញ្ញាប័ត្របរិញ្ញាប័ត្ររបស់បេក្ខជន នៅខែ កក្កដា ឆ្នាំ ២០០៤ ប៉ុណ្ណោះទេ តែអង្គភាពនេះក៏បានផ្អែកផងដែរលើការវាយតម្លៃពីមុខងារនីមួយៗដែលម្ចាស់បណ្តឹងឧទ្ធរណ៍ បានបំពេញដើម្បីវាយតម្លៃពីបទពិសោធន៍របស់គាត់។ ហេតុដូចនេះ អង្គបុរេជំនុំជម្រះអាចវាយតម្លៃបានថា ការសម្រេចចាប់គិតពីចំណុចចាប់ផ្តើមនៃការគណនារយៈពេលបទពិសោធន៍ការងាររបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ពិតជាមិនបានធ្វើឱ្យប៉ះពាល់ដល់ការចុះឈ្មោះរបស់គាត់ក្នុងបញ្ជីមេធាវីនោះទេ។ ដោយហេតុថា បញ្ហានៃចំណុចចាប់ផ្តើមគណនាលើបទពិសោធន៍ការងាររបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ អនុលោមតាមប្រការ ២.២ នៃបទបញ្ជារដ្ឋបាល មិនពាក់ព័ន្ធនឹងសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍នេះ ហើយហេតុដូច្នេះ វាពិតជាមិនមានភាពចាំបាច់ ឬមានប្រយោជន៍សម្រាប់អង្គបុរេជំនុំជម្រះក្នុងការពិនិត្យលើចំណុចមួយនេះនោះទេ។

## IV. សេចក្តីសន្និដ្ឋាន

២៥. អង្គបុរេជំនុំជម្រះយល់ឃើញថា ម្ចាស់បណ្តឹងឧទ្ធរណ៍ មិនបានបង្ហាញឱ្យឃើញថា អង្គភាពគាំពារការការពារក្តីបានប្រព្រឹត្តកំហុសពាក់ព័ន្ធនឹងការកំណត់ពីលក្ខណៈវិនិច្ឆ័យក្នុងការទទួលបានសិទ្ធិធ្វើជាតំណាងជនសង្ស័យ ជនត្រូវចោទ និងជនជាប់ចោទក្រីក្រ នៅចំពោះមុខ អ.វ.ត.ក ឬក្នុងការវាយតម្លៃពីបទពិសោធន៍ការងាររបស់គាត់ ដើម្បីជាប្រយោជន៍ដល់ការពិនិត្យនូវលក្ខណៈវិនិច្ឆ័យទាំងអស់នេះឡើយ។

២៦. ដូច្នេះ បណ្តឹងឧទ្ធរណ៍របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ត្រូវបានបដិសេធចោល។

## V. ផ្នែកសម្រេចសេចក្តី

**ផ្អែកតាមសំអាងហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័នថា៖**

**ប្រកាស**ទទួលយកបណ្តឹងឧទ្ធរណ៍នេះ។

*សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គភាពគាំពារការការពារក្តី ឆ្លើយតបទៅនឹងសំណើសុំចុះឈ្មោះក្នុងបញ្ជីមេធាវីបរទេស*

01109423



ច្រានចោលអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍នេះ។

ដោយអនុលោមតាមវិធាន ៧៧ ១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។

**ភ្នំពេញ ថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០១៥**

**អង្គបុរេជំនុំជម្រះ**

**ប្រធាន**

| | | | | |
|---|---|---|---|---|
| **ប្រាក់ គឹមសាន** | **Olivier BEAUVALLET** | **នេយ ថុល** | **Steven J. BWANA** | **ហួត វុទ្ធី** |